long beach unified school district

OFFICE OF EQUITY, ACCESS, COLLEGE & CAREER READINESS
Volunteers in Public Schools

VIPS make a difference

Parent University

# វិធីណែនាំអំពីរបៀបដាក់ពាក្យសុំធ្វើជា អ្នកស្ម័គ្រចិត្ត (VIPS) នៅតាមសាលារៀន

ក្រដាសបំពេញដាក់ពាក្យ គឺតំរូវធ្វើ បួន ឆ្នាំម្តង

**មុខងារទទួលខុសត្រូវរបស់អ្នកស្ម័គ្រចិត្តថ្មី**
**អ្នកស្ម័គ្រចិត្ត ដែលមានបំណងជួយសាលារៀន នឹងធ្វើតាមអ្វីដូចតទៅ** …

**ឆ្លើយបំពេញ**ក្រដាសដាក់ពាក្យ VIPS ជាភាសា អង់គ្លេស ឬ ខ្មែរ ។

**ទៅសុំយក**លទ្ធផលជោះស្បែកពិនិត្យរោគរបេង មិនគិតថ្លៃ ដែលផ្តល់ឡើងដោយក្រសួងអប់រំ ឪស្រ្ទីគ ពីវេជ្ជបណ្ឌិតរបស់អ្នក ឬ នៅតាមមន្ទីរ គ្លីននិក ណាមួយដែលមានឈ្មោះវាយនៅលើក្រដាសភ្ជាប់ជាមួយ ។ ការបញ្ជាក់អំពីលទ្ធផលរោគរបេង គឺត្រូវបង្ហាញ **ថ្ងៃខែបានទទួលការជោះស្បែក ថ្ងៃខែបានទទួលការពិនិត្យ (ចន្លោះពេល 48-72 ម៉ោង) លទ្ធផលបង្ហាញ និង ឈ្មោះមន្ទីរពេទ្យ ឬ គ្លីននិក** ។ បើមិនចង់ធ្វើការជោះស្បែកទេ នៅមានមធ្យោបាយម្យ៉ាងផ្សេង ដែលអាចប្រើជំនួសបាន គឺការឆ្លើយសំនួរនៅលើក្រដាស ហៅ TB Risk Assessment Questionnaire Certification ដែលអ្នកត្រូវបំពេញ **ក្រោមការមើលខុសត្រូវពីបុគ្គលិកពេទ្យ ដែលមានសញ្ញាប័ត្រត្រឹមត្រូវ** ។ សូមចំណាំថា លទ្ធផលបញ្ជាក់អំពីការគ្មានរោគរបេង ដែលអាចប្រើការបាន គឺត្រូវមានបង្ហាញក្នុងចំនួន 60 ថ្ងៃ បន្ទាប់ពីបានផ្ញើក្រដាសដាក់ពាក្យទៅកាន់ការិយាល័យ VIPS ប្រចាំក្រសួងអប់រំ ឪស្រ្ទីគ ផុតទៅ ។ លទ្ធផល X-ray បញ្ជាក់ការគ្មានរោគរបេង គឺត្រូវបង្ហាញ ថ្ងៃ ខែ ក្នុងចំនួន 6 ខែនៅពេលបានដាក់ពាក្យបំពេញក្រដាសផុតទៅ ។

**នាំយក**ក្រដាសបំពេញត្រឹមត្រូវ ក្រដាស គូពី ប័ណ្ណបើកបរ ឬ អាយឌី (ID) និង ក្រដាសបង្ហាញលទ្ធផលរោគរបេងទៅប្រគល់ជូនអ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀនរបស់អ្នក ។ ការឆ្លើយបំពេញមិនត្រឹមត្រូវ ឬ ការមិនបានបង្ហាញលទ្ធផលគ្រប់គ្រាន់ នឹងបណ្តាលអោយមានការពន្យារពេល ។ បើអ្នកនឹងស្ម័គ្រជួយនៅតាមសាលារៀនផ្សេងជាច្រើនកន្លែង គឺ**ក្រដាសបំពេញនឹងត្រូវប្រគល់ទៅកាន់សាលារៀនមួយៗទាំងអស់នោះ** ។

- អ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀន នឹងផ្ញើអ្វីដូចតទៅទៅកាន់ការិយាល័យ Equity, Access, College & Career Readiness:
  1. ក្រដាសដាក់ពាក្យ ដែលអ្នកបានឆ្លើយបំពេញត្រឹមត្រូវ
  2. ក្រដាសបង្ហាញលទ្ធផល រោគរបេង ឬ ក្រដាសឆ្លើយសំនួរ TB Risk Assessment Questionnaire Certificate
  3. ក្រដាស គូពី ប័ណ្ណបើកបរ ឬ អាយឌី (ID)
- ការិយាល័យ VIPS ប្រចាំក្រសួងអប់រំ ឪស្រ្ទីគ នឹងរត់ការក្រដាស ពិនិត្យបញ្ជាក់អំពីលទ្ធផលរោគរបេង និង ឆែកមើលតាម Megan's Law ។
- ការិយាល័យ VIPS ប្រចាំក្រសួងអប់រំ ឪស្រ្ទីគ នឹងផ្ញើត្រឡប់ទៅវិញអំពីក្រដាសបង្ហាញការទទួលយល់ព្រម និង ប័ណ្ណ VIPS ទៅកាន់អ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀន ។
- អ្នកស្ម័គ្រចិត្តនឹងបានទទួលការទាក់ទងពីអ្នកចាត់ចែងកម្មវិធី VIPS នៅតាមសាលារៀន និង ប្រហែលជាអាចចាប់ផ្តើមស្ម័គ្រធ្វើការបានភ្លាមនៅក្នុងសាលារៀន បន្ទាប់ពីបានចូលរួមស្តាប់ក្នុងកម្មវិធីពន្យល់វិន័យ និង ទទួលជាកូនសៀវភៅវិន័យផុតទៅ ។
- ដើម្បីរក្សាភាពសន្តិសុខដល់សិស្ស និង មនុស្សទូទៅក្នុងសាលារៀន គឺអ្នកត្រូវសរសេរកត់ឈ្មោះរាល់លើក នៅពេលអ្នកចូល និង ចេញពីលារៀន និង ត្រូវពាក់ប័ណ្ណ VIPS ជាឈ្មោះរបស់អ្នកនៅពេលអ្នកនៅនៅក្នុងសាលារៀន ។ **ហាមមិនអោយ**យកប័ណ្ណ VIPS របស់អ្នកចេញក្រៅសាលារៀន លើកលែងតែនៅពេល ដែលអ្នកត្រូវធ្វើដំណើរទៅជាមួយសិស្សតាមកន្លែងផ្សេងៗ ។ អ្នកក៏មិនត្រូវអោយមនុស្សផ្សេងខ្ចីប័ណ្ណឈ្មោះរបស់អ្នកពាក់ប្រើនោះទេ ។

**ចំពោះអ្នកស្ម័គ្រចិត្ត ដែលត្រឡប់មកជួយវិញ ជាអតីត ឬ សុំផ្លាស់ទៅជួយនៅតាមសាលារៀនផ្សេង**

1. **បើត្រឡប់ទៅស្ម័គ្រជួយនៅក្នុងសាលារៀនដដែល** - សូមទៅជួបអ្នកចាត់ចែងកម្មវិធី VIPS នៅសាលារៀននោះ ដើម្បីសួរអំពីអ្វីទាក់ទងថ្ងៃខែធ្វើការពិនិត្យរោគរបេង ដោយប្រើសំណុំរឿងធ្លាប់មានស្រាប់មកហើយ ។ បើលទ្ធផលអំពីរោគរបេងនៅតែប្រើការបាន គឺអ្នកប្រហែលជាអាចចាប់ផ្តើមស្ម័គ្រជួយនៅតាមសាលារៀននោះបានភ្លាម ។ ក្រដាសបំពេញដាក់ពាក្យថ្មី គឺតំរូវធ្វើ បួន ឆ្នាំម្តង ។
2. **បើសុំផ្លាស់ទៅស្ម័គ្រជួយនៅតាមសាលារៀនផ្សេង** - សូមឆ្លើយបំពេញក្រដាសដាក់ពាក្យ VIPS ជាថ្មី ។ បន្ទាប់ពីនាយកសាលា និង អ្នកចាត់ចែងកម្មវិធី VIPS បានចុះហត្ថលេខាពីលើហើយ គឺគេនឹងផ្ញើក្រដាសដាក់ពាក្យថ្មីនោះទៅកាន់ការិយាល័យ VIPS ប្រចាំក្រសួងអប់រំ ឪស្រ្ទីគ ។ ការបង្ហាញក្រដាស គូពី អំពីរោគ របេង គឺមិនចាំបាច់ទេ អោយតែលទ្ធផលនៅពេលសព្វថ្ងៃនេះអាចប្រើការបាន ។ បន្ទាប់ពីបានទទួលរត់ការហើយ គឺសំបុត្របង្ហាញការទទួលយល់ព្រម រួមទាំងប័ណ្ណឈ្មោះនឹងផ្ញើទៅកាន់សាលារៀនវិញ ។ **ប័ណ្ណឈ្មោះ គឺមិនអាចប្រើពីសាលារៀនមួយទៅសាលារៀនមួយផ្សេងបានទេ** ។

**បើលទ្ធផលអំពីរោគរបេងមានពេលហួសថ្ងៃខែ ដែលប្រើការលែងកើត (បួន ឆ្នាំម្តង សំរាប់ការជោះស្បែក ឬ ការឆ្លើយសំនួរនៅលើក្រដាស Risk Assessment)** - ក្រដាសបំពេញដាក់ពាក្យថ្មីនឹងតំរូវធ្វើ ។ ការបញ្ជាក់អំពីលទ្ធផលរោគរបេង គឺត្រូវមានដូចជា: ថ្ងៃខែបានធ្វើការជោះស្បែក ថ្ងៃខែបានទទួលការពិនិត្យ (ចន្លោះពេល 48-72 ម៉ោង) លទ្ធផលបង្ហាញ និង ឈ្មោះមន្ទីរពេទ្យ ឬ គ្លីននិក ។ បើមានសំនួរអំពី X-ray គឺអាចទាក់ទងបានតាមលេខទូរស័ព្ទ (562) 997-8307 ។

**អាស័យដ្ឋាននៅលើប័ណ្ណបើកបរ ឬ អាយឌី (ID)** ត្រូវបង្ហាញភាពដូចគ្នានៅលើក្រដាសបំពេញដាក់ពាក្យ ។ បើផ្លាស់អាស័យដ្ឋាន គឺអ្នកត្រូវបញ្ជាក់អំពីអាស័យដ្ឋានថ្មី ដោយគឺបភ្ជាប់ជាភស្តុតាងមកជាមួយផង ។ **រូបថតនៅក្នុងប័ណ្ណបើកបរ ឬ អាយឌី (ID) ត្រូវបង្ហាញមុខច្បាស់** ។

*ការចាត់ចែងរត់ការក្រដាសបំពេញដាក់ពាក្យ VIPS នឹងចំណាយពេលប្រហែល 2 សប្តាហ៍ ឬ លើស ។ សូមអ្នកមេត្តាលៃលកបំពេញព័ត៌មានអោយបានត្រឹមត្រូវ រួមទាំងបង្ហាញការចុះហត្ថលេខារបស់អ្នកផង ដើម្បីជៀសវាងការពន្យារពេល ។ សូមអរគុណចំពោះការកាន់ចិត្តអត់ធ្មត់ពីអ្នក ។

*សូមចំណាំថា ក្រដាសឆ្លើយបំពេញទាំងប៉ុន្មាន ដែលបង្ហាញអំពីការជាប់ទោស គឺតំរូវអោយមានការបញ្ជាក់ជាក្រដាសភស្តុតាងមកពីតុលាការ និង ត្រូវគឺបភ្ជាប់មកជាមួយផង ។ ពេលបន្ថែមនឹងត្រូវការសំរាប់ស្រាវជ្រាវមើលជាបន្ត ។ បើមានសំនួរទាក់ទងក្រដាសបំពេញដាក់ពាក្យ កិច្ចការស្ម័គ្រជួយ និង អ្វីផ្សេងៗទៀត សូមទាក់ទងអ្នកស្រី Dulnari Edirisinghe-Aga ដែលមានមុខងារជាអ្នកគ្រប់គ្រងកម្មវិធី VIPS ប្រចាំក្រសួងអប់រំ ឪស្រ្ទីគ តាមលេខទូរស័ព្ទ (562) 997-8307 ។